## តើកម្ពុជាអាចទទួលបានផលប្រយោជន៍អ្វីខ្លះពី CDM ?

CDM អាចលើកទឹកចិត្តឱ្យមានការវិនិយោគលើគំរោងមួយចំនួន ដែលអាចកាត់បន្ថយ ស្រូបយក ឬបញ្ចៀសការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ។ ការវិនិយោគនៅក្នុងគំរោងបែបនេះអាចនាំឆ្ពោះទៅរក :

- ការផ្ទេរបច្ចេកវិជ្ជាស្អាតមិនបំផ្លាញបរិស្ថាន និងការផ្ទេរធនធានហិរញ្ញវត្ថុ
- ការផលិត និងការប្រើប្រាស់ថាមពលប្រកបដោយនិរន្តរភាព
- ការបង្កើនការសន្សំសំចៃថាមពល និងប្រសិទ្ធិភាពថាមពល
- ការកាត់បន្ថយភាពក្រីក្រតាមរយៈការបង្កើតការងារ និងប្រាក់ចំណូល
- ផលចំណេញផ្នែកសង្គម និងបរិស្ថាន
- ការអភិរក្សជីវៈចំរុះ និងការស្តារប្រព័ន្ធអេកូឡូស៊ី ។

មានប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ដែលអាចទទួលអនុវត្តនូវគំរោង CDM ដែលមានសក្តានុពលនានា ហើយប្រការនេះនឹងនាំឱ្យមានការប្រកួតប្រជែងគ្នា ដើម្បីទាក់ទាញវិនិយោគគិនផ្នែក CDM ។ បច្ចុប្បន្នប្រទេសកម្ពុជាកំពុងអនុវត្តគំរោង *ការកសាងសមត្ថភាពសំរាប់យន្តការអភិវឌ្ឍន៍ស្អាត* (Capacity Development for the Clean Development Mechanism, CD4CDM) ដើម្បីពង្រឹងសមត្ថភាព ក្នុងការទាក់ទាញវិនិយោគិនផ្នែក CDM មកកម្ពុជា ។




*CDM អាចជួយជំរុញការវិនិយោគទុនក្នុងវិស័យថាមពលកើតឡើងវិញ ដូចជាថាមពលព្រះអាទិត្យជាដើម*

## តើ CDM មានវិធានអ្វីខ្លះ ?

មានវិធាន និងបែបបទអន្តរជាតិជាច្រើន ដែលត្រូវអនុវត្តតាម ដើម្បីធានាថាគំរោងណាមួយអាចទទួលយកបាន នៅក្រោមលក្ខខណ្ឌ CDM និងអាចបង្កើត CERs ។ ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ត្រូវតែជាអ្វីដែលកើតបន្ថែម បើប្រៀបធៀបទៅនឹងការបំភាយឧស្ម័នដែលនឹងកើតឡើងដោយគ្មានគំរោង (លក្ខខណ្ឌគោល) ហើយគំរោងទាំងនោះត្រូវតែគាំទ្រគោលដៅអភិវឌ្ឍន៍ដោយចីរភាព របស់ប្រទេសជាម្ចាស់ផ្ទះ ។ ក្រៅពីនេះនៅមានបែបបទផ្សេងទៀត សំរាប់ការអនុម័ត (ដោយប្រទេសជាម្ចាស់ផ្ទះ និងអ្នកផ្តល់សុពលភាពឯករាជ្យ) ការត្រួតពិនិត្យ ការផ្ទៀងផ្ទាត់ និងការបញ្ជាក់ ។ លោកអ្នកអាចរកពត៌មានបន្ថែមស្តីពីវិធានទាំងនេះ នៅក្នុងកូនសៀវភៅរបស់កម្មវិធីបរិស្ថានសហប្រជាជាតិឈ្មោះ សេចក្តីផ្តើមស្តីពី CDM រឺលោកអ្នកអាចអានគេហទំព័ររបស់យើង ខ្ញុំតាមអាស័យដ្ឋាន : www.camclimate.org.kh

## វដ្តគំរោង CDM




*វដ្តគំរោង CDM ដូចមានបង្ហាញក្នុងរូបភាពខាងលើមាន ៧ ដំណាក់កាលជាមូលដ្ឋាន : ការរៀបចំ និងបង្កើតគំរោង, ការអនុម័តនៅថ្នាក់ជាតិ, ការផ្តល់សុពលភាព/ការចុះបញ្ជី, ការផ្តល់ហិរញ្ញប្បទានដល់គំរោង, ការត្រួតពិនិត្យ, ការផ្ទៀងផ្ទាត់/បញ្ជាក់, ការចេញឱ្យ CER ។ សកម្មភាព ៤ ដំបូងត្រូវធ្វើមុនការអនុវត្តគំរោង ដោយឡែកសកម្មភាព ៣ បន្ទាប់ត្រូវអនុវត្តក្នុងអំឡុងពេលដំណើរការរបស់គំរោង ។*

## តើអ្នកណាខ្លះនឹងចូលរួមអនុវត្តគំរោង ហើយដោយរបៀបណា ?

**រដ្ឋាភិបាល** : តួនាទីសំខាន់របស់រដ្ឋាភិបាលនៅក្នុងគំរោង CDM គឺតាមរយៈ DNA ។ បណ្តាស្ថាប័នរដ្ឋាភិបាលត្រូវធ្វើការជាមួយគ្នា ដើម្បីបង្កើត DNA ហើយរៀបចំលក្ខណៈវិនិច្ឆ័យ និងដំណើរការ ដើម្បីវាយតំលៃរាល់គំរោង CDM ដែលស្នើឡើង ។ មន្ត្រីរដ្ឋាភិបាលក៏អាចធ្វើការជាមួយផ្នែកឯកជន និងអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីកំណត់រកនូវគំរោង CDM ដែលមានសក្តានុពល និងផ្សព្វផ្សាយគំរោងទាំងនោះទៅឱ្យវិនិយោគិនផ្នែក CDM ផងដែរ ។




*គំរោងស្តារ និងដាំព្រៃឡើងវិញ អាចស្នើសុំជាគំរោង CDM*

**វិស័យឯកជន** : ប្រការសំខាន់គឺថា CDM ជាមធ្យោបាយមួយរបស់វិស័យឯកជន ។ វិស័យឯកជនក្នុងស្រុកអាចបង្កើតគំរោង CDM របស់ពួកគេផ្ទាល់ ហើយលក់គំរោងទាំងនោះទៅឱ្យវិនិយោគិន រឺក៏អាចក្លាយជាដៃគូរជាមួយអ្នកបង្កើតគំរោងអន្តរជាតិនានាផងដែរ ។ ផ្នែកឯកជនក៏នឹងចូលរួមផ្តល់មតិយោបល់លើដំណើរការវាយតំលៃ និងលក្ខណៈវិនិច្ឆ័យសំរាប់អនុម័តគំរោង CDM ទាំងឡាយ ដែលស្នើឡើង ។

**អង្គការមិនមែនរដ្ឋាភិបាល** : អាចចូលរួមយ៉ាងសកម្មក្នុងការកំណត់គំរោង CDM និងធ្វើការជាមួយវិនិយោគិនក្នុងស្រុក រឺបរទេស ដើម្បីរៀបចំគំរោងទាំងនោះឡើង ។ អង្គការមិនមែនរដ្ឋាភិបាលនឹងមានឱកាសផ្តល់មតិយោបល់ផងដែរ ក្នុងការរៀបចំលក្ខណៈវិនិច្ឆ័យនៃការអភិវឌ្ឍន៍ដោយចីរភាពសំរាប់ CDM ។

**អ្នកផ្តល់ជំនួយ** : អាចចូលរួមក្នុង CDM ។ ប៉ុន្តែ វិធានអន្តរជាតិបានចែងថា គំរោង CDM មិនអាចដកយកជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) មកប្រើឡើយ ។ អ្នកផ្តល់ជំនួយក៏អាចចូលរួមក្នុងការងារកសាងសមត្ថភាព ជាពិសេសក្នុងការកំណត់ និងរៀបចំគំរោង CDM ដែលមានសក្តានុពល ។




*អង្កាមអាចយកមកប្រើប្រាស់ជាជីវម៉ាស សំរាប់គំរោងថាមពលកើតឡើងវិញ ដែលជាគំរោងអាចទទួលយកបានថាជាគំរោង CDM*

## សេចក្តីផ្តើម

ដោយទទួលស្គាល់ពីភាពចាំបាច់ក្នុងការដោះស្រាយបញ្ហាកើនឡើងនៃឧស្ម័នផ្ទះកញ្ចក់នៅលើពិភពលោក និងឥទ្ធិពលរបស់វាទៅលើអាកាសធាតុនៃភពផែនដី រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័នដល់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ កាលពីថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ១៩៩៥ ហើយបានចូលជាសមាជិកពិធីសារក្យូតូនៅថ្ងៃទី ៤ ខែកក្កដា ឆ្នាំ ២០០២ ។ ក្រសួងបរិស្ថានដើរតួជាជនបង្គោលសំរាប់អនុសញ្ញា និងពិធីសារខាងលើ ។ មកទល់បច្ចុប្បន្ន ក្រសួងបរិស្ថានបានអនុវត្តការងារជាច្រើនក្នុងវិស័យប្រែប្រួលអាកាសធាតុ ក្នុងនោះរួមមានការធ្វើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ និងការរៀបចំរបាយការណ៍ជាតិលើកទី ១ ដើម្បីដាក់ជូនទៅអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ។

## ការប្រែប្រួលអាកាសធាតុនៅកម្ពុជា



តំបន់ឆ្នេរកម្ពុជាងាយរងគ្រោះថ្នាក់ដោយការកើនឡើងកំពស់ទឹកសមុទ្រ ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

ក្រសួងបរិស្ថានបានបង្កើតការិយាល័យប្រែប្រួលអាកាសធាតុជាផ្លូវការ នៅថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០០៣ ដើម្បីសំរបសំរួលរាល់សកម្មភាពដែលទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុនៅក្នុងប្រទេស ។ ការិយាល័យប្រែប្រួលអាកាសធាតុនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់របស់រាជរដ្ឋាភិបាល ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាល ផ្នែកឯកជន សហគមន៍មូលដ្ឋាន អ្នកផ្តល់ជំនួយ និងអង្គការអន្តរជាតិនានា ដើម្បីសំរបសំរួល និងអនុវត្តនូវរាល់គោលនយោបាយប្រែប្រួលអាកាសធាតុជាតិ គំរោងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ គំរោងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការធ្វើសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ គំរោងកសាងសមត្ថភាព និងបណ្តុះបណ្តាល ការរៀបចំរបាយការណ៍ជាតិ និងកាតព្វកិច្ចដទៃទៀត ក្នុងនាមជាជនបង្គោលនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ ។ លើសពីនេះ ការិយាល័យនឹងសំរបសំរួលនូវរាល់សកម្មភាពដែលទាក់ទងជាមួយយន្តការអភិវឌ្ឍន៍ស្អាត ជួសមុខឱ្យក្រសួងបរិស្ថាន ដែលទើបត្រូវបានតែងតាំង ជាស្ថាប័នបណ្តោះអាសន្ន ទទួលបន្ទុកយន្តការអភិវឌ្ឍន៍ស្អាត តាមរយៈសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៣ ។



បុគ្គលិករបស់ការិយាល័យប្រែប្រួលអាកាសធាតុក្នុងវគ្គបណ្តុះបណ្តាលមួយ

## គំរោងការកសាងសមត្ថភាពសំរាប់យន្តការអភិវឌ្ឍន៍ស្អាត (CD4CDM)

គំរោងការកសាងសមត្ថភាពសំរាប់យន្តការអភិវឌ្ឍន៍ស្អាត គឺជាគំរោងរបស់កម្មវិធីបរិស្ថានសហប្រជាជាតិ ដោយមានជំនួយហិរញ្ញវត្ថុពីរដ្ឋាភិបាលហុឡង់ ។ មានប្រទេសចំនួន ១២ ចូលរួមអនុវត្តគំរោងនេះ ហើយកម្ពុជាគឺជាប្រទេសមួយ ក្នុងចំណោមបណ្តាប្រទេសបី ដែលត្រូវ បានជ្រើសរើសនៅអាស៊ី ។

គំរោង CD4CDM មានបំណងជួយប្រទេសកម្ពុជា ឱ្យចូលរួមនៅក្នុងយន្តការអភិវឌ្ឍន៍ស្អាត តាមរយៈ :

- បង្កើតការយល់ដឹងឱ្យបានទូលំទូលាយអំពីកាលានុវត្តភាពនានា ដែលផ្តល់ដោយយន្តការអភិវឌ្ឍន៍ស្អាត
- រៀបចំស្ថាប័នចាំបាច់មួយចំនួន សំរាប់វាយតំលៃ និងអនុម័តលើគំរោងយន្តការអភិវឌ្ឍន៍ស្អាតនានា
- កសាងសមត្ថភាពដើម្បីរៀបចំ និងអនុវត្តគំរោងនានា ក្រោមយន្តការអភិវឌ្ឍន៍ស្អាត ។



សិក្ខាសាលាថ្នាក់តំបន់លើកទី ១ ស្តីពីការកសាងសមត្ថភាពសំរាប់យន្តការអភិវឌ្ឍន៍ស្អាត នៅប្រទេសថៃ ពីថ្ងៃទី ១៦ ដល់ ១៨ មករា ២០០៣

## តើកម្ពុជាត្រូវធ្វើអ្វីខ្លះដើម្បីអាចចូលរួមអនុវត្តយន្តការអភិវឌ្ឍន៍ស្អាត ?

ដើម្បីចូលរួមក្នុងគំរោង CDM បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដូចកម្ពុជា ចាំបាច់ត្រូវបង្កើតអាជ្ញាធរជាតិ CDM មួយ (Designated National Authority, DNA) ដើម្បីវាយតំលៃ និងអនុម័តលើបណ្តាគំរោង CDM សំដៅធានាថា គំរោង CDM ទាំងនោះពិតជាឆ្លើយតបទៅនឹងរាល់ទិសដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ប្រទេស ។ ប្រទេសម្ចាស់ផ្ទះត្រូវតែផ្តល់សច្ចាប័នជាមុនដល់ពិធីសារក្យូតូ ហើយនិងចូលរួមអនុវត្តគំរោង CDM ដោយស្ម័គ្រចិត្ត ។ បច្ចុប្បន្ន ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នដល់ពិធីសារក្យូតូរួចហើយ ព្រមទាំងកំពុងអនុវត្តគំរោង CD4CDM ដែលនឹងជួយរៀបចំនូវអាជ្ញាធរជាតិ CDM មួយ និងកសាងសមត្ថភាពកម្ពុជា សំរាប់ចូលរួមក្នុង CDM ។


*សំរាប់ពត៌មានបន្ថែមសូមទាក់ទង ការិយាល័យប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន*

*អាគារលេខ៤៨ វុក្ខវិថី ព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ*

*ទូរស័ព្ទ/ទូរសារ: (៨៥៥-២៣) ២១៨-៣៧០*

*អ៊ីម៉ែល*: **cceap@online.com.kh**

**Website: www.camclimate.org.kh**


# ការិយាល័យប្រែប្រួលអាកាសធាតុកម្ពុជា

# យន្តការអភិវឌ្ឍន៍ស្អាតនៅកម្ពុជា

កញ្ញា ២០០៣

## តើយន្តការអភិវឌ្ឍន៍ស្អាតជាអ្វី ?

នៅក្រោមពិធីសារក្យូតូ បណ្តាប្រទេសអភិវឌ្ឍន៍បានប្តេជ្ញាចិត្តកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ជាផ្លូវការ ក្នុងបរិមាណកំណត់មួយ ។ បណ្តាប្រទេសទាំងនោះមានជំរើសមួយចំនួន ដើម្បីសំរេចកិច្ចការនេះ ពោលគឺពួកគេអាចកាត់បន្ថយ បញ្ជៀស រឺស្រូបយកឧស្ម័នផ្ទះកញ្ចក់ នៅក្នុងប្រទេសរបស់ខ្លួន រឺនៅក្រៅប្រទេស តាមរយៈការវិនិយោគនៅក្នុងប្រទេសផ្សេងទៀត ។ ដំណើរការវិនិយោគទុននៅប្រទេសកំពុងអភិវឌ្ឍន៍ត្រូវបានគេហៅថា "**យន្តការអភិវឌ្ឍន៍ស្អាត**" (Clean Development Mechanism, CDM) ។ ប្រទេសជាម្ចាស់ផ្ទះត្រូវទទួលយកគំរោងទាំងនោះមកអនុវត្តដោយស្ម័គ្រចិត្ត ហើយគំរោងត្រូវតែគាំទ្រដល់ទិសដៅនៃការអភិវឌ្ឍន៍ដោយចីរភាព ។

## តើយន្តការអភិវឌ្ឍន៍ស្អាតប្រព្រឹត្តទៅយ៉ាងដូចម្តេច ?

យន្តការអភិវឌ្ឍន៍ស្អាតផ្តល់នូវមធ្យោបាយមួយដល់បណ្តាប្រទេសជឿនលឿន រឺក្រុមហ៊ុនរបស់ប្រទេសទាំងនោះ ដើម្បីផ្តល់ហិរញ្ញប្បទានដល់វិធានការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់នានា នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ។ ផលចំណេញដែលក្រុមហ៊ុន រឺប្រទេសជាអ្នកធ្វើវិនិយោគទុនទទួលបានគឺ ការកាត់បន្ថយការបញ្ចេញឧស្ម័ន ដែលបានបញ្ជាក់ (certified emission reduction) ហៅកាត់ថា CER ដែលអាចប្រើប្រាស់សំរាប់គោលដៅកាត់បន្ថយឧស្ម័នរបស់ពួកគេ ។ មានវិធីជាច្រើន ដែលវិនិយោគិនផ្នែក CDM អាចចូលរួម ។ វិយោគិនអាចចេញថ្លៃវិនិយោគទាំងស្រុងសំរាប់គំរោង CDM ហើយទទួលបានមកវិញនូវ CER និងផលចំណេញផ្សេងទៀតពីការបណ្តាក់ទុនលើគំរោង ។ វិនិយោគិនខ្លះទៀតប្រហែលគ្រាន់តែផ្តល់ហិរញ្ញប្បទានសំរាប់តែតំលៃ CER (ផ្តល់ឱ្យជាមុនទាំងស្រុង រឺបន្តិចម្តងៗ) ។ នៅក្នុងករណីភាគច្រើន តំលៃរបស់ CER មានតិចជាងតំលៃវិនិយោគសរុបរបស់គំរោង ។

ឧទាហរណ៍មួយចំនួននៃគំរោងវិនិយោគ CDM មាន : ថាមពលកើតឡើងវិញ, ប្រសិទ្ធិភាពថាមពល និងការសន្សំសំចៃថាមពល, ការប្តូរប្រេងឥន្ធនៈ, ការកាត់បន្ថយការបញ្ចេញឧស្ម័នពីសំណល់ រឺពីសកម្មភាពដឹកជញ្ជូន ព្រមទាំងការស្តារ និងការដាំព្រៃឡើងវិញ ។